**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

**សំណុំរឿងរដ្ឋប្បវេណី**
លេខ ១១២៨ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២
**សាលក្រមរដ្ឋប្បវេណី**
**លេខ ៦១ -ជ-**
ចុះថ្ងៃ០៧ ខែកញ្ញា ឆ្នាំ២០២៣

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្តាល

បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ
នាថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៣ និងថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង ០២ និង ០០ នាទី រសៀល។

**ចៅក្រម**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

ដើមចោទឈ្មោះ [redacted] **ហេលីន** ភេទស្រី អាយុ២៣ឆ្នាំ ជនជាតិខ្មែរ មុខរបរបុគ្គលិកវាយកូនហ្គោល កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted]

លោកស្រីមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] ហេលីន។

-ចុងចម្លើយឈ្មោះ [redacted]**មន** ភេទប្រុស អាយុ៥១ឆ្នាំ មុខរបរលក់ដូរ និងឈ្មោះ [redacted]**ស្រី** ភេទស្រី អាយុ៥៣ឆ្នាំ ជនជាតិខ្មែរ មុខរបរលក់ដូរ មានទីលំនៅបច្ចុប្បន្ននៅ[redacted]

លោកស្រីមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted]ន និងឈ្មោះ [redacted]ស្រី។

## <u>អង្គហេតុ និងចំណុចវិវាទ</u>

**១.ការទាមទារដោយដើមចោទ៖**

សុំឱ្យតុលាការចេញសាលក្រមសម្រេច៖

ក-សុំសិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted]រ៉ូហ្សា ភេទស្រី កើតថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩។

ខ-សុំឱ្យឈ្មោះ [redacted]ន និងឈ្មោះ [redacted]ស្រី ប្រគល់កូនស្រីឈ្មោះ [redacted]រ៉ូហ្សា មកឱ្យដើមចោទ។

**២.ការពន្យល់ត្រួសៗអំពីរឿងក្តី**

រឿងក្តីនេះ គូភាគីបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាត្រឹមត្រូវតាមច្បាប់ មានសំបុត្រអាពាហ៍ពិពាហ៍លេខ ៣៤ សៀវភៅអាពាហ៍ពិពាហ៍លេខ ០១/២០១៧ ឆ្នាំ២០១៧ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៧។ ក្នុងអំឡុងពេលរស់នៅជាមួយគ្នា ភាគីដើមចោទ និងចុងចម្លើយបង្កើតបានកូនស្រីម្នាក់ឈ្មោះ [redacted]រ៉ូហ្សា ភេទស្រី ជន



Scanned with CamScanner

ជាតិខ្មែរ កើតនៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩។ នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨ ដើមចោទ និងចុងចម្លើយ បានលែងលះគ្នាដោយស្ម័គ្រចិត្តនៅត្រឹមភូមិឃុំ។ នៅឆ្នាំ២០២២ ឈ្មោះ [redacted]សុវណ្ណារ៉ា បានទទួលមរណភាព។ បន្ទាប់ពីឈ្មោះ [redacted]សុវណ្ណារ៉ា បានទទួលមរណភាព ដើមចោទក៏ទៅយកកូនស្រីមកគ្រប់គ្រង ប៉ុន្តែត្រូវបានឈ្មោះ [redacted]សុភាព និងឈ្មោះ [redacted]សារ៉ាត់ រួមទាំងឪពុកម្តាយក្មេកខ្លួនឈ្មោះ [redacted]មន និងឈ្មោះ [redacted]ស្រី មិនព្រម ប្រគល់កូនមកឱ្យដើមចោទនោះទេ។

**៣.ចំណុចវិវាទ៖** តើភាគីដើមចោទ ឬចុងចម្លើយ ជាអ្នកមានសិទ្ធិអំណាចមេបាលើឈ្មោះ [redacted] រ៉ូហ្សា តាមច្បាប់?

**៤.ការអះអាងរបស់គូភាគី៖**

-ដើមចោទឈ្មោះ [redacted] ហេលីន បានធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនសូមរក្សាខ្លឹមសារ និងការទាមទារដូចក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ និងកាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ ដដែល។ ខ្លួនសុំសិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] រ៉ូហ្សា ភេទស្រី កើតថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ និងសុំឱ្យឈ្មោះ [redacted]ន និងឈ្មោះ [redacted]ស្រី ប្រគល់កូនស្រីឈ្មោះ [redacted] រ៉ូហ្សា មកឱ្យខ្លួនជាម្តាយបង្កើតជាអ្នកគ្រប់គ្រង ថែរក្សាកូនស្រីរបស់ខ្លួន។

លោកស្រីមេធាវី[redacted]និងលោកមេធាវី[redacted] ជាមេធាវីតំណាងដោយអាណត្តិ បានធ្វើសេចក្តីថ្លែងការណ៍ថា ដើមចោទឈ្មោះ [redacted] ហេលីន និងប្តីឈ្មោះ [redacted]សុវណ្ណារ៉ា បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាត្រឹមត្រូវតាមច្បាប់ មានសំបុត្រអាពាហ៍ពិពាហ៍លេខ ៣៤ ចុះថ្ងៃទី១៦ ឧសភា ឆ្នាំ២០១៧។ មូលហេតុដែលកូនក្តីខ្លួនស្នើសុំឈប់រស់នៅជាអនីតិសង្វាសជាមួយប្តីឈ្មោះ [redacted]សុវណ្ណារ៉ា ដោយហេតុថាបន្ទាប់ពីរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាការរស់នៅជាប្តីប្រពន្ធនេះ កូនក្តីខ្លួន និងប្តីឈ្មោះ [redacted] សុវណ្ណារ៉ា ចេះតែឈ្លោះប្រកែក ទាស់ទែងគ្នា រស់នៅមិនចុះសម្រុងនឹងគ្នា ទើបកូនក្តីខ្លួនមិនអាចបន្តរស់នៅជាមួយតទៅទៀតបាន ក៏សម្រេចចិត្តធ្វើកិច្ចសន្យាឈប់រួមរស់ជាប្តីប្រពន្ធ ដោយស្ម័គ្រចិត្តនៅត្រឹមភូមិឃុំ ។

ក្នុងអំឡុងពេលរួមរស់នឹងគ្នាជាប្តីប្រពន្ធនេះ កូនក្តីខ្លួន និងប្តីឈ្មោះ [redacted]សុវណ្ណារ៉ា បានបង្កើតបានកូនស្រីម្នាក់ឈ្មោះ [redacted]រ៉ូហ្សា ភេទស្រី កើតថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ មានសំបុត្រកំណើតលេខៈ ១៩៧ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ ។ ក្រោយពីសម្រាលកូនរួចហើយដោយសារថា កូនក្តីខ្លួន និងប្តី ត្រូវជាប់រវល់ ធ្វើការមិនមានពេលគ្រប់គ្រាន់ ក៏ឱ្យពូ និងមីងថ្លៃឈ្មោះ [redacted]សុភាព និងឈ្មោះ [redacted]សារ៉ាត់ ជាអ្នកមើលថែកូនសីរបស់កូនក្តីខ្លួន ដោយកូនក្តីខ្លួនបានបើកប្រាក់ខែក្នុងមួយខែចំនួន ១០០ (មួយរយ) ដុល្លារអាមេរិកឱ្យទៅពួកគាត់សំរាប់ការមើលថែកូន ចំពោះសំភារៈប្រើប្រាស់ទឹកដោះគោ និងការចំណាយសព្វបែបយ៉ាងគឺក្នុងក្តីខ្លួន ជាអ្នករ៉ាប់រងទាំងអស់ ។ មូលហេតុដែលកូនក្តីខ្លួនស្នើសុំអំណាចមេបាលើកូនស្រីឈ្មោះ [redacted]រ៉ូហ្សា ភេទស្រី កើតថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ ដោយហេតុថាក្រោយពីឈប់រស់នៅជាអនីតិសង្វាស កូនស្រីឈ្មោះ [redacted] រ៉ូហ្សា គឺបានរស់នៅជាមួយ ប្តីឈ្មោះ [redacted] សុវណ្ណារ៉ា ដោយសារការទទួលបានអំណាចមេបាតាមការពិភាក្សាជាមួយនឹងកូនក្តីខ្លួន ។ ក្រោយលែងលះ កូនក្តីខ្លួនក៏បានធ្វើការទំនាក់ទំនងទៅឈ្មោះ [redacted]សុវណ្ណារ៉ា ដែលជាអតីតប្តី ដើម្បីសុំជួប និងសុំទៅលេងកូនស្រីឈ្មោះ [redacted] រ៉ូហ្សា ប៉ុន្តែឈ្មោះ [redacted] សុវណ្ណារ៉ា មិនបានអនុញ្ញាតឱ្យជួប និងប្រាស្រ័យទាក់ទងរហូត ។

ប៉ុន្តែក្រោយមកនៅអំឡុងឆ្នាំ២០២២ ឈ្មោះ [redacted]សុវណ្ណារ៉ា ក៏បានទទួលមរណភាព ។ នៅពេលដែលកូនក្តីខ្លួន បានទទួលដំណឹងថា ឈ្មោះ [redacted]សុវណ្ណារ៉ា បានទទួលមរណភាព ក្នុងនាមជាម្តាយបង្កើតកូនក្តីខ្លួនបានធ្វើ



Scanned with CamScanner

ការទំនាក់ទំនងទៅចុងចម្លើយឈ្មោះ [redacted]មន និងឈ្មោះ [redacted]ស្រី ដែលជាអតីតឪពុកម្ដាយក្មេក ដើម្បីសុំជួប និងសុំទៅលេងកូនស្រីឈ្មោះ [redacted]រ៉ូហ្សា ប៉ុន្តែចុងចម្លើយឈ្មោះ [redacted]មន និងឈ្មោះ [redacted]ស្រី នៅតែមិនព្រមឱ្យជួប។ ហេតុនេះហើយក្នុងនាមជាម្ដាយ កូនក្ដីខ្លួនស្នើសុំឱ្យតុលាការសម្រេចអំពីអ្នកមានសិទ្ធិអំណាចមេបាមកលើកូនស្រីឈ្មោះ [redacted] រ៉ូហ្សា នេះ ព្រោះកូនក្ដីខ្លួនមានពេលវេលាគ្រប់គ្រាន់ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូន (ភាពជាម្ដាយ ម្ដាយ និងកូន ត្រូវនៅជាមួយគ្នា មិនអាចបំបែកគ្នាបានទេ) មានលទ្ធភាព និងចំណូលគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់លើការចំណាយផ្សេងៗសម្រាប់ចិញ្ចឹមបីបាច់ថែរក្សាកូន បច្ចុប្បន្នកូនក្ដីខ្លួនកំពុងបម្រើការងារឱ្យក្រុមហ៊ុន [redacted]ទទួលបានប្រាក់ខែចន្លោះពី ៩០០ (ប្រាំបួនរយ) ដុល្លារអាមេរិក ទៅ ១០០០ (មួយពាន់) ដុល្លារអាមេរិក ក្នុង០១ (មួយ) ខែ។ ម្យ៉ាងបើយោងតាមមាត្រា ៩៨៧ នៃក្រមរដ្ឋប្បវេណី ដោយសារកូនក្ដីខ្លួនជាម្ដាយរបស់កូន ដូច្នេះកូន ក្ដីខ្លួនមានសិទ្ធិចិញ្ចឹមបីបាច់ថែរក្សាកូន ដោយហេតុថា ទាំងអតីតប្ដី និងអតីតឪពុកម្ដាយក្មេក នៅអំឡុងពេលដែលពួកគាត់ថែរក្សាកូន គឺពួកគាត់មិនដែលឱ្យកូនក្ដីខ្លួនជួបប្រាស្រ័យទាក់ទងកូននោះទេ ហើយព្យាយាមផ្ដាច់ទំនាក់ទំនងម្ដាយ និងកូន ធ្វើអោយកូនមិនស្គាល់ម្ដាយ និងមិនតាមម្ដាយ មិនមែនដោយសារកូនក្ដីខ្លួនទុកកូនចោល ឬបោះបង់កូននោះទេ ដោយផ្ទុយទៅនឹងមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី ។

ហេតុដូចនេះ ក្នុងនាមខ្លួនជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted]ហេលីន សូមសំណូមពរតុលាការមេត្តាសម្រេចតាមការទាមទាររបស់កូនក្ដីខ្លួន ដូចមានក្នុងពាក្យបណ្ដឹង ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ២០២២ ។

-ចុងចម្លើយឈ្មោះ [redacted]មន និងឈ្មោះ [redacted] ស្រី ដោយមានលោកស្រីមេធាវី [redacted]ជាអ្នកតំណាងដោយអាណត្តិ បានធ្វើសេចក្ដីថ្លែងការណ៍ថា ខ្លួនសូមរក្សាខ្លឹមសារ និងការទាមទារដូចក្នុងកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ និងកាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ ដដែល។ ខ្លួនសូមបដិសេធចំពោះការស្នើសុំសិទ្ធិអំណាចមេបាលើចៅស្រីឈ្មោះ [redacted] ហេលីន កើតនៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ ដោយសារចៅស្រីរបស់ខ្លួនបានរស់នៅជាមួយខ្លួនតាំងពីអាយុជិត ០៣ ខែ មកម្ល៉េះ។ ខ្លួនសូមបញ្ជាក់ថា កូនរបស់ខ្លួនឈ្មោះ [redacted]សុវណ្ណារ៉ា និងឈ្មោះ [redacted] ហេលីន ជាប្ដីប្រពន្ធនឹងគ្នា ហើយក្នុងអំឡុងឆ្នាំ២០១៨ ពួកគាត់បានរស់នៅបែកគ្នាដោយធ្វើការលែងលះគ្នានៅត្រឹមភូមិឃុំ។ បន្ទាប់ពីរស់នៅបែកគ្នាមួយរយៈក្រោយមកក៏បានសះជានឹងគ្នា ហើយរស់នៅជាមួយគ្នាជាប្ដីប្រពន្ធវិញ និងបង្កើតបានកូនស្រីម្នាក់ឈ្មោះ [redacted] រ៉ូហ្សា ។ លុះដល់អំឡុងឆ្នាំ២០២១ ឈ្មោះ [redacted]សុវណ្ណារ៉ា និងឈ្មោះ [redacted] ហេលីន ក៏បានបែកបាក់គ្នាម្ដងទៀត។ បន្ទាប់ពីរស់នៅបែកបាក់គ្នាកូនប្រុសរបស់ខ្លួនក៏បានយកគ្រួសារថ្មី។ ចៅស្រីឈ្មោះ [redacted] រ៉ូហ្សា មិនបានរួមរស់ជាមួយម្ដាយនោះទេ គឺរស់នៅជាមួយខ្លួនតាំងពីតូចដល់សព្វថ្ងៃនេះ។ ខ្លួនយល់ព្រម និងអនុញ្ញាតឱ្យឈ្មោះ [redacted] ហេលីន ត្រូវជាម្ដាយអាចយកកូនទៅលេងបាន ប៉ុន្តែបន្ទាប់ពីយកកូនទៅលេងហើយ ត្រូវតែប្រគល់កូនស្រីខាងលើមកឱ្យខ្លួនជាអ្នកមើលថែ គ្រប់គ្រង និងបីបាច់ វិញ ហើយនៅពេលដែលចៅមានអាយុ ០៥ឆ្នាំ ខ្លួននឹងប្រគល់សិទ្ធិអំណាចមេបាទៅឱ្យដើមចោទជាអ្នកគ្រប់គ្រង ប៉ុន្តែខ្លួនសុំសិទ្ធិប្រាស្រ័យទាក់ទង និងសុំសិទ្ធិយកចៅមកលេងបើមានការនឹករលឹក។ បើចៅស្រីរបស់ខ្លួនយល់ព្រមទៅរស់នៅជាមួយម្ដាយ ខ្លួនយល់ព្រមឱ្យចៅទៅរស់នៅជាមួយម្ដាយគាត់ ប៉ុន្តែចៅស្រីពុំព្រមទៅនៅជាមួយម្ដាយនោះទេ គឺគាត់គ្រាន់តែឃើញមុខម្ដាយគឺគាត់យំតែម្ដង។ សព្វថ្ងៃនេះ ខ្លួនមានចៅចំនួន ០៣ នាក់ ហើយខ្លួនជាអ្នកលក់បន្លែក្នុងផ្សារ។ ចំណែកឯការអះអាងរបស់ដើមចោទថា បានផ្ដល់ប្រាក់ចំនួន ១០០ ដុល្លារអាមេរិក ឱ្យទៅឈ្មោះ [redacted]សុភាព និងឈ្មោះ [redacted]សារ៉ាត់ ជារៀងរាល់ខែ ថាជូរនឹងការមើលថែរក្សាចៅស្រីឈ្មោះ [redacted] រ៉ូហ្សា នោះគឺពុំពិតនោះទេ គឺគាត់



Scanned with CamScanner

ផ្តល់ប្រាក់ឱ្យបន្តិចបន្តួចតែប៉ុណ្ណោះ។ កូនប្រុសរបស់ខ្លួនឈ្មោះ [redacted] សុវណ្ណារ៉ា បានទទួលមរណភាពកាលពីថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០២២។

## សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរគូភាគី និងពិនិត្យភស្តុតាង ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា៖

១-ពាក្យបណ្តឹងចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២ របស់ដើមចោទឈ្មោះ [redacted] ហោលីន មានលក្ខណៈត្រឹមត្រូវបញ្ជាក់ថា សាលាដំបូងខេត្តកណ្តាល មានដែនសមត្ថកិច្ច ដើម្បីវិនិច្ឆ័យស្របតាមច្បាប់នូវពាក្យបណ្តឹង ហើយចេញសាលក្រមបានតាមមាត្រា ៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២-ដើមចោទឈ្មោះ [redacted] ហោលីន និងឈ្មោះ [redacted] សុវណ្ណារ៉ា បានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ មានសំបុត្រអាពាហ៍ពិពាហ៍លេខ ៣៤ សៀវភៅអាពាហ៍ពិពាហ៍លេខ ០១/២០១៧ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៧។

៣-អំឡុងពេលរស់នៅជាមួយគ្នា គូភាគីមានកូនចំនួន ០១ នាក់ឈ្មោះ [redacted] រ៉ូហ្សា ភេទស្រី កើតថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ ផ្អែកតាមបញ្ជីកំណើតលេខ ១៩៧ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំគគីរ បញ្ជាក់ថា ដើមចោទឈ្មោះ [redacted] ហោលីន ត្រូវជាម្តាយបង្កើត និងឈ្មោះ [redacted] សុវណ្ណារ៉ា ត្រូវឪពុកបង្កើតដែលបច្ចុប្បន្នបានទទួលមរណភាព មានសំបុត្រមរណភាពលេខ ៣៦ សៀវភៅមរណភាពលេខ ០២/២០២២ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ ពិតប្រាកដមែន។

៤-ភាគីដើមចោទសុំសិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] រ៉ូហ្សា ភេទស្រី កើតថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ ដោយមូលហេតុថា ប្តីរបស់ខ្លួនឈ្មោះ [redacted] សុវណ្ណារ៉ា ដែលត្រូវជាឪពុករបស់កូនឈ្មោះ [redacted] រ៉ូហ្សា បានទទួលមរណភាពហើយ ពុំអាចប្រើប្រាស់អំណាចមេបាបានទេ។ គប្បីតុលាការពិចារណា និងសម្រេចតាមការទាមទាររបស់ដើមចោទ ស្របតាមមាត្រា ១០៣៦ នៃក្រមរដ្ឋប្បវេណី។

៥-ដើមចោទស្នើសុំឱ្យចុងចម្លើយឈ្មោះ [redacted] មន និងឈ្មោះ [redacted] ស្រី ប្រគល់កូនស្រីឈ្មោះ [redacted] រ៉ូហ្សា មកឱ្យខ្លួនជាអ្នកគ្រប់គ្រង និងថែរក្សា វិញ ដោយហេតុថា សព្វថ្ងៃនេះកូនស្រីឈ្មោះ [redacted] រ៉ូហ្សា កំពុងរស់នៅជាមួយចុងចម្លើយដែលត្រូវជា តា-យាយ របស់ឈ្មោះ [redacted] រ៉ូហ្សា ប៉ុន្តែចុងចម្លើយពុំព្រមប្រគល់ចៅស្រីខាងលើមកឱ្យដើមចោទជាម្តាយបង្កើតគ្រប់គ្រង និងថែរក្សា នោះទេ ដោយសុំសិទ្ធិមើលថែចៅស្រីរហូតដល់ចៅស្រីមានអាយុ ០៥ ឆ្នាំ ទើបយល់ព្រមប្រគល់ចៅស្រីឱ្យទៅម្តាយបង្កើតវិញ។ តុលាការយល់ឃើញថា អ្នកដែលមានសិទ្ធិអំណាចមេបាលើកូន គឺជាម្តាយបង្កើតរបស់កូន ហេតុដូច្នេះ គប្បីតុលាការពិចារណា និងសម្រេចតាមការទាមទាររបស់ដើមចោទ ស្របតាមមាត្រា ១០៤៧ នៃក្រមរដ្ឋប្បវេណី។

៦-ប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សេចក្តីសម្រេចបញ្ចប់

**១**-កំណត់យកដើមចោទឈ្មោះ [redacted] **ហោលីន** ភេទស្រី កើតនៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០០០ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted] ត្រូវជា**ម្តាយបង្កើត** ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] **រ៉ូហ្សា** ភេទស្រី កើតនៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ ស្របតាមមាត្រា ១០៣៦ នៃក្រមរដ្ឋប្បវេណី។

**២**-បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] **មន** និងឈ្មោះ [redacted] **ស្រី** ប្រគល់ចៅឈ្មោះ [redacted] **រ៉ូហ្សា** ភេទស្រី កើតនៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ មកឱ្យដើមចោទឈ្មោះ [redacted] **ហោលីន** **ត្រូវជាម្តាយបង្កើត** ស្របតាមមាត្រា ១០៤៧ នៃក្រមរដ្ឋប្បវេណី។



Scanned with CamScanner

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

សាលក្រមនេះបញ្ចប់ការទាញហេតុផលផ្ទាល់មាត់នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៣។

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

**បានឃើញ**

**ចៅក្រម**

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃព្រហស្បតិ៍ ៧រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

កណ្តាល , ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner